ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង
ខេត្តបន្ទាយមានជ័យ

តុលាការរដ្ឋប្បវេណី
សាលក្រមរដ្ឋប្បវេណីលេខ: ២៧ -ក-/២០៥
ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២០

រឿងក្តី: បណ្តឹងទាមទារដី
សំណុំរឿងរដ្ឋប្បវេណីលេខ: ១០១៤
ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៩

# សាលក្រម

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តបន្ទាយមានជ័យ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២០ នៅសាលសវនាការទី៣ នៃសាលាដំបូងខេត្តបន្ទាយមានជ័យ ។

## ចៅក្រមជំនុំជម្រះ

ឯកឧត្តម [redacted] ប្រធានសាលាដំបូង

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូង

**សហដើមចោទ:**

-ឈ្មោះ [redacted] សុខឡេង ភេទស្រី អាយុ ៣២ឆ្នាំ ជនជាតិខ្មែរ។

-ឈ្មោះ [redacted] ស្រីនី ភេទស្រី អាយុ ៣០ឆ្នាំ ជនជាតិខ្មែរ។

-ឈ្មោះ [redacted] ស្រីណយ ភេទស្រី អាយុ ២៨ឆ្នាំ ជនជាតិខ្មែរ។

-ឈ្មោះ [redacted] ស្រីនិត ភេទស្រី អាយុ ២៧ឆ្នាំ ជនជាតិខ្មែរ។

អាសយដ្ឋាន: ភូមិវាលវង់ ឃុំសាស្តា ស្រុកសំពៅលូន ខេត្តបាត់ដំបង។

-អ្នកតំណាងដោយអាណត្តិ: លោកមេធាវី [redacted] និងលោកមេធាវី [redacted]។

ការិយាល័យ: [redacted] ។

**ចុងចម្លើយ**: ឈ្មោះ [redacted] ខេន ភេទស្រី អាយុ ៦២ឆ្នាំ ជនជាតិខ្មែរ អាសយដ្ឋាន [redacted] ។

អ្នកតំណាងដោយអាណត្តិ: លោកមេធាវី [redacted] ការិយាល័យ [redacted] ។

## អង្គហេតុ និងចំណុចវិវាទ

### ១.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ:

១.១.សុំឲ្យតុលាការទទួលស្គាល់ដីដែលមានទំហំ ៦០ម៉ែត្រ គុណនឹង ១០០ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់នឹងឈ្មោះ [redacted] ម៉ៅ ខាងត្បូងទល់នឹងឈ្មោះ [redacted] ម៉ៅ ខាងកើតទល់នឹងឈ្មោះ [redacted] សារ៉ូ និងខាងលិចទល់នឹងឈ្មោះ [redacted] សំអុល មានទីតាំងស្ថិតនៅភូមិព្រៃគប់ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ជាទ្រព្យឯកជនរបស់ឈ្មោះ [redacted]ផល ជាសពឪពុកសហដើមចោទ ។

១.២.សុំទាមទារទ្រព្យឯកជនរបស់សពឪពុកសហដើមចោទ មកឲ្យសហដើមចោទជាម្ចាស់កម្មសិទ្ធិ ។

១.៣.ឲ្យចុងចម្លើយសងសំណងជម្ងឺចិត្តនិងការខាតបង់ពេលវេលាជាប្រាក់ចំនួន១០.០០០.០០០ (ដប់លាន) រៀល ។

១.៤.ឲ្យចុងចម្លើយទទួលបន្ទុកប្រាក់ប្រដាប់ក្តី ។

### ២.ដំណើររឿងក្តី និង ចំណុចវិវាទ:

**២.១.ការសង្ខេបអំពីរឿងក្តី:**

កាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៨ ឈ្មោះ [redacted]រិន ភេទប្រុស បានប្រគល់ដីចំនួន ១ កន្លែងទំហំទទឹង ៦០ ម៉ែត្រ ១០០ ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់នឹងឈ្មោះ [redacted] ម៉ៅ ខាងត្បូងទល់នឹងឈ្មោះ [redacted] ម៉ៅ ខាងកើតទល់នឹងឈ្មោះ [redacted] សារ៉ូ និងខាងលិចទល់នឹងឈ្មោះ [redacted] សំអុល មានទីតាំងស្ថិតនៅភូមិព្រៃគប់ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ឲ្យមកឪពុកសហចុងចម្លើយឈ្មោះ [redacted] ផល ដើម្បីគ្រប់គ្រងជាកម្មសិទ្ធិ ហើយចាប់តាំងពីពេលប្រគល់ដីនេះរួច ឪពុកសហចុងចម្លើយក៏បានកាន់កាប់រហូតមកនិងពុំដែលមានបញ្ហាអ្វីឡើយ រីឯចុងចម្លើយឈ្មោះ [redacted] ខេន ដែលត្រូវជាម្តាយចុងរបស់សហចុងចម្លើយ គឺគាត់ពុំដែលបានដឹងពីរឿងឪពុកសហចុងចម្លើយមានដីនេះឡើយ ចំណែកសហចុងចម្លើយវិញគឺបានដឹងនិងធ្លាប់បានទៅដល់ទីតាំងដីផ្ទាល់ទៀតផង ។ លុះនៅក្នុងអំឡុងឆ្នាំ២០១៧ ឪពុកសហចុងចម្លើយក៏បានរស់នៅបែកពីចុងចម្លើយឈ្មោះ [redacted] ខេន ដោយសារមានជម្លោះក្នុងគ្រួសារបន្តិចបន្តួច ហើយគាត់រស់នៅផ្ទះយាយរបស់សហចុងចម្លើយ និងនៅបន្ទាយទាហានព្រោះគាត់ជាទាហាន ក្រោយមកឪពុកសហចុងចម្លើយបានធ្លាក់ខ្លួនឈឺ ហើយគាត់បានប្រាប់មេរបស់គាត់ថា បើស្លាប់ទៅសូមឲ្យយកសពរបស់គាត់ទៅធ្វើបុណ្យនៅផ្ទះប្អូន ឬ ផ្ទះកូន។ លុះនៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨ ឪពុកសហចុងចម្លើយក៏បានទទួលមរណភាពបាត់ទៅ ហើសពរបស់គាត់ត្រូវបានក្រុមការងារគាត់បានដឹកមកធ្វើបុណ្យនៅផ្ទះពូសហចុងចម្លើយ ដែលត្រូវជាប្អូនរបស់គាត់ ហើយក៏បានធ្វើបុណ្យជូនគាត់តាមប្រពៃណីនៅភូមិផ្សារកណ្តាល សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត

ទំព័រទី២

ខេត្តបន្ទាយមានជ័យ ។ ក្រោយពេលឪពុកសហាចុងចម្លើយទទួលមរណភាពបាត់ទៅសហាចុងចម្លើយក៏បានទៅគ្រប់គ្រងលើដីចំនួន ១ កន្លែងទំហំទទឹង ៦០ ម៉ែត្រ ១០០ ម៉ែត្រ ហិកតា មានព្រំប្រទល់ខាងជើងទល់នឹងឈ្មោះ [redacted] ម៉ៅ ខាងត្បូងទល់នឹងឈ្មោះ [redacted] ម៉ៅ ខាងកើតទល់នឹងឈ្មោះ [redacted] សាវ៉ូ និងខាងលិចទល់នឹងឈ្មោះ [redacted] សំអុល មានទីតាំងស្ថិតនៅភូមិព្រៃគប់ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ បន្តពីគាត់រហូត តែពេលនោះដែរគឺសហាចុងចម្លើយពុំបានដឹងថាមានទំហំប៉ុន្មានទេ ចំណែកចុងចម្លើយឈ្មោះ [redacted] ខេន ជាម្តាយចុងសហាចុងចម្លើយ គឺពុំបានដឹងពីរឿងដីខាងលើនេះឡើយ ។ បន្ទាប់មកចុងចម្លើយឈ្មោះ [redacted] ខេន និងសហាចុងចម្លើយជាតំណាងឲ្យប្អូនចំនួន ៣ នាក់ទៀត ក៏បានធ្វើការបែងចែកនូវមត៌កដែលជាទ្រព្យសម្បត្តិឪពុកសហាចុងចម្លើយ ដើម្បីជៀសវាងមានបញ្ហា និងគ្នានៅថ្ងៃក្រោយ ក្នុងពេលធ្វើការបែងចែកគឺចុងចម្លើយបានប្រគល់ដីទំហំ ២០ ម៉ែត្រ គុណ ២៥០ ម៉ែត្រ ស្ថិតនៅភូមិ សន្តិភាព ឃុំទួលពង្រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ឲ្យមកសហាចុងចម្លើយ តែដោយការស្មោះត្រង់សច្ចរិតរបស់សហាចុងចម្លើយ សហាចុងចម្លើយក៏ប្រាប់ចុងចម្លើយថាឪពុកសហាចុងចម្លើយមានដីមួយកន្លែងទៀតស្ថិតនៅភូមិព្រៃគប់ សង្កាតផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យដែលដីនេះគឺខ្ញុំជាអ្នកគ្រប់គ្រង ហើយក្នុងពេលនោះ ចុងចម្លើយក៏បានសុខចិត្តយល់ព្រមប្រគល់ឲ្យមកសហាចុងចម្លើយទៀត ព្រោះកន្លងមកសហាចុងចម្លើយ គឺធ្វើឡើងតាមរយៈលិខិតធ្វើអំណោយបែងចែកដីផ្តាច់ ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០១៨ រវាងសហាចុងចម្លើយ និងគាត់ ([redacted] ខេន) ដោយគាត់ប្រាប់ថា បើគាត់រកឃើញលិខិតឬឯកសារពាក់ព័ន្ធនិងដីដែលស្ថិនៅភូមិព្រៃគប់ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យនេះ គាត់និងប្រគល់ឲ្យសហាចុងចម្លើយ ដើម្បីធ្វើការកាត់ឈ្មោះ ឬផ្ទេរឲ្យដើម្បីងាយស្រួលគ្រប់គ្រងជាកម្មសិទ្ធិនៅថ្ងៃក្រោយ ក្រោយពីបែងចែករួច ចុងចម្លើយឈ្មោះ [redacted] ខេន ដែលត្រូវជាម្តាយរបស់សហាចុងចម្លើយបានសុំឲ្យឈ្មោះ [redacted] សុខុម ដែលជាកូនរបស់គាត់ទៅចុះមើលដីនេះជាមួយនិងសហាចុងចម្លើយ ក្រោយមកទៀត ដីចំនួន ១ កន្លែងទំហំទទឹង ៦០ ម៉ែត្រ ១០០ ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់នឹងឈ្មោះ [redacted] ម៉ៅ ខាងត្បូងទល់នឹងឈ្មោះ [redacted] ម៉ៅ ខាងកើតទល់នឹងឈ្មោះ [redacted] សាវ៉ូ និងខាងលិចទល់នឹងឈ្មោះ [redacted] សំអុល មានទីតាំងស្ថិតនៅភូមិព្រៃគប់ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ គឺសហាចុងចម្លើយនៅតែគ្រប់គ្រងបន្តដដែលព្រោះមានការបែងចែក និងបានធ្វើលិខិតស្នាមមានសាក្សីដឹងឮត្រឹមត្រូវហើយ ដោយសហាចុងចម្លើយបានអាស្រ័យផលលើដីនេះទៀតផង ។ លុះពេលចុងចម្លើយឈ្មោះ [redacted] ខេន ដែលត្រូវជាម្តាយចុងរបស់សហាចុងចម្លើយរកឃើញឯកសារពាក់ព័ន្ធទៅ និងដីទំហំទទឹង ៦០ ម៉ែត្រ ១០០ ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់នឹងឈ្មោះ [redacted] ម៉ៅ ខាងត្បូងទល់នឹងឈ្មោះ [redacted] ម៉ៅ ខាងកើតទល់នឹងឈ្មោះ [redacted] សាវ៉ូ និងខាងលិចទល់នឹងឈ្មោះ [redacted] សំអុល មានទីតាំងស្ថិតនៅ

ភូមិព្រៃគប់ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ស្រាប់តែគាត់មិនព្រមប្រគល់ឯកសារនេះឲ្យមកសហចុងចម្លើយដើម្បីឲ្យសហចុងចម្លើយកាន់កាប់ស្របច្បាប់ ដូចដែលគាត់បាននិយាយកន្លងទៀយ មិនតែប៉ុណ្ណោះគាត់ ([redacted] ខេន) បានមានគំនិតទុច្ចរិតដោយយកឯកសារដីនេះ ទៅរត់ការជាមួយអាជ្ញាធរសង្កាត់ និងក្រុងដើម្បីយកដីមកគ្រប់គ្រងនិងដាក់ឈ្មោះខ្លួនជាម្ចាស់ទៅវិញ តែសហចុងចម្លើយបានដឹង ហើយចុងចម្លើយក៏បានដាក់ពាក្យមកតុលាការទៀតដើម្បីហាមឃាត់សហចុងចម្លើយមិនឲ្យធ្វើសកម្មភាពនៅលើនេះទៀតផង ។ សហចុងចម្លើយសូមបញ្ជាក់ថា ដីទំហំទទឹង ៦០ ម៉ែត្រ ១០០ ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់នឹងឈ្មោះ [redacted] ម៉ៅ ខាងត្បូងទល់នឹងឈ្មោះ [redacted] ម៉ៅ ខាងកើតទល់នឹងឈ្មោះ [redacted] សារ៉ូ និងខាងលិចទល់នឹងឈ្មោះ [redacted] សំអុល មានទីតាំងស្ថិតនៅភូមិព្រៃគប់ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ គឺជាកេរ្តិ៍របស់ឪពុកសហចុងចម្លើយយ៉ាងពិតប្រាកដ និងមិនមែនជាទ្រព្យរួមរវាងចុងចម្លើយ និងឪពុកសហចុងចម្លើយឡើយ ព្រោះដីនេះកន្លងមកចុងចម្លើយពុំបានដឹងពីរឿងនេះឡើយ ម្យ៉ាងទៀតពាក្យស្នើសុំបញ្ជាក់ការកាន់កាប់ និងប្រើប្រាស់ដីធ្លី ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០០៤ គឺមានតែឈ្មោះឪពុកសហចុងចម្លើយតែម្នាក់គត់ជាម្ចាស់ដី ហើយមិនមានឈ្មោះសហចុងចម្លើយនៅក្នុងលិខិតពាក្យស្នើសុំបញ្ជាក់ការកាន់កាប់និង ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៤ ឡើយ ។

**២.២.អង្គហេតុដែលគ្មានវិវាទៈ**

-គូភាគីបានទទួលស្គាល់ថាមានពាក្យស្នើសុំការបញ្ជាក់ការកាន់កាប់ និងប្រើប្រាស់ដីធ្លីលេខ ១០៦០ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៤ ចុះហត្ថលេខាដោយលោក [redacted] ណាំហេង មេឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ។

-គូភាគីបានទទួលស្គាល់ថាមានលិខិតធ្វើអំណោយបែងចែកដីផ្ទាល់លេខ ៣៧៦/១៨ ឃទព ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ បញ្ជាក់ដោយលោក ទឹម ម៉ន មេឃុំទួលពង្រ ។

-គូភាគីទទួលស្គាល់ថាមានដីទំហំ ៦០ម៉ែត្រ គុណនឹង ១០០ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់នឹងឈ្មោះ [redacted] ម៉ៅ ខាងត្បូងទល់នឹងឈ្មោះ [redacted] ម៉ៅ ខាងកើតទល់នឹងឈ្មោះ [redacted] សារ៉ូ និងខាងលិចទល់នឹងឈ្មោះ [redacted] សំអុល មានទីតាំងស្ថិតនៅភូមិព្រៃគប់ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

**២.៣.ចំណុចវិវាទៈ**

-មានវិវាទអំពីការទាមទារបញ្ជាក់ទទួលស្គាល់ដីទំហំ ៦០ម៉ែត្រ គុណនឹង ១០០ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់នឹងឈ្មោះ [redacted] ម៉ៅ ខាងត្បូងទល់នឹងឈ្មោះ [redacted] ម៉ៅ ខាងកើតទល់នឹងឈ្មោះ [redacted] សារ៉ូ និងខាងលិចទល់នឹងឈ្មោះ [redacted] សំអុល មានទីតាំងស្ថិតនៅភូមិព្រៃគប់ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ជាកម្មសិទ្ធិរបស់



Scanned with CamScanner

សហដើមចោទ ។ ដោយសហដើមចោទអះអាងថាចុងចម្លើយបានព្រមព្រៀងប្រគល់ដីខាងលើនេះមកឲ្យសហដើមចោទតាមរយៈលិខិតធ្វើអំណោយបែងចែកដីផ្តាច់លេខ ៣៧៦/១៨ ឃទព ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ បញ្ជាក់ដោយលោក [redacted] ម៉ន មេឃុំទួលពង្រ រីឯចុងចម្លើយអះអាងថា ដែលចុងចម្លើយប្រគល់ឲ្យទៅសហដើមចោទពុំមែនជាដីដែលសហដើមចោទទាមទារនេះទេ ហើយដីដែលសហដើមចោទទាមទារនេះជាទ្រព្យរួមរវាងចុងចម្លើយ និងសពឈ្មោះ [redacted] ផល ជាឪពុករបស់សហដើមចោទ ។

*តើដីដែលសហដើមចោទទាមទារខាងលើនេះ ជាដីដែលស្ថិតនៅក្នុងចំណុចទី២ នៃលិខិតធ្វើអំណោយបែងចែកដីផ្តាច់លេខ ៣៧៦/១៨ ឃទព ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ បញ្ជាក់ដោយមេឃុំទួលពង្រ ដែលចុងចម្លើយបានប្រគល់ឲ្យ សហដើមចោទដែរឬទេ? បើដីដែលសហដើមចោទទាមទារជាដីផ្សេងក្រៅពីដីដែលមាននៅក្នុងចំណុចទី២ នៃលិខិតធ្វើអំណោយបែងចែកដីផ្តាច់លេខ ៣៧៦/១៨ ឃទព ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ បញ្ជាក់ដោយមេឃុំទួលពង្រ តើដីដែលសហដើមចោទទាមទារនេះជាទ្រព្យដោយឡែករបស់សពឈ្មោះ យ៉ាន ផល ឬជាទ្រព្យរួមរវាងចុងចម្លើយ និងសពឈ្មោះ [redacted] ផល ?*

**២.៤.ការអះអាងរបស់ភាគីស្តីពីចំណុចវិវាទៈ**

**-ការអះអាងរបស់ដើមចោទៈ** ដីទំហំ ៦០ម៉ែត្រ គុណនឹង ១០០ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់នឹងឈ្មោះ [redacted] ម៉ៅ ខាងត្បូងទល់នឹងឈ្មោះ [redacted] ម៉ៅ ខាងកើតទល់នឹងឈ្មោះ [redacted] សារ៉ូ និងខាងលិចទល់នឹងឈ្មោះ [redacted] សំអុល មានទីតាំងស្ថិតនៅភូមិព្រៃគប់ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ជាទ្រព្យដោយឡែករបស់សពឪពុកខ្លួនឈ្មោះ [redacted] ផល មិនមែនជាទ្រព្យរួមរវាងឪពុកខ្លួន និងចុងចម្លើយនោះទេ ហើយដីខាងលើនេះត្រូវបានចុងចម្លើយយល់ព្រមប្រគល់ឲ្យមកសហចុងចម្លើយ តាមរយៈលិខិតធ្វើអំណោយបែងចែកដីផ្តាច់ ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០១៨ បញ្ជាក់ដោយមេឃុំទទួលពង្រ រួចហើយ ។ ម៉្យាងវិញទៀតតាមពាក្យស្នើសុំបញ្ជាក់ការកាន់កាប់ និងប្រើប្រាស់ដីធ្លីលេខ ១០៦០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៩ បញ្ជាក់ដោយមេឃុំប៉ោយប៉ែត គឺមានតែឈ្មោះ [redacted] ផល តែម្នាក់គត់ជាម្ចាស់ដីចំណុចនេះ បញ្ជាក់ថាដីនេះជាទ្រព្យរបស់ឈ្មោះ [redacted] ផល តែម្នាក់គត់ ។ ចំពោះទំហំដីដែលបានដាក់ក្នុងលិខិតធ្វើអំណោយបែងចែកដីផ្តាច់ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ ដែលបានដាក់ថាដីមានទំហំ ៥០ម៉ែត្រ គុណនឹង ៦០ម៉ែត្រ គឺចេះតែដាក់ស្មានៗតែប៉ុណ្ណោះ ពុំបានវាស់វែងឲ្យបានត្រឹមត្រូវទេ និងពុំមានឯកសារយោងច្បាស់លាស់ ហើយការដែលដើមចោទទាមទារតាមពាក្យបណ្តឹងថាដីនេះមានទំហំ ៦០ម៉ែត្រ គុណនឹង ១០០ម៉ែត្រនេះគឺដោយសារតែដើមចោទទើបបានឃើញឯកសារជាពាក្យស្នើសុំបញ្ជាក់ការកាន់កាប់ និងប្រើប្រាស់ដីធ្លីលេខ ១០៦០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៩ បង្ហាញថា ដីនេះមានទំហំ ៦០ម៉ែត្រ គុណនឹង ១០០ម៉ែត្រ ។



Scanned with CamScanner

-ការអះអាងរបស់សហចុងចម្លើយ: ដីទំហំ ៦០ម៉ែត្រ គុណនឹង ១០០ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់នឹងឈ្មោះ [redacted] ម៉ៅ ខាងត្បូងទល់នឹងឈ្មោះ [redacted] ម៉ៅ ខាងកើតទល់នឹងឈ្មោះ [redacted] សារ៉ូ និងខាងលិចទល់នឹងឈ្មោះ [redacted] សំអុល មានទីតាំងស្ថិតនៅភូមិព្រៃគប់ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ គឺជាដីចុងចម្លើយ និងឈ្មោះ [redacted] ផល បានទិញរួមគ្នាពីឈ្មោះ [redacted] រិន ក្រោយពេលដែលចុងចម្លើយ និងឈ្មោះ [redacted] ផល រួមរស់ជាមួយគ្នាកាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០២ ដោយផ្អែកតាមពាក្យស្នើសុំសែន ចំណុចនេះបញ្ជាក់ថា ដីនេះជាទ្រព្យរួមរបស់ចុងចម្លើយ និងឈ្មោះ [redacted] ផល ស្របតាមមាត្រា ៩៧២ និងមាត្រា ៩៧៣ នៃក្រមរដ្ឋប្បវេណី ។ ដីដែលដើមចោទទាមទារខាងលើនេះ ពុំមែនជាដីដែលចុងចម្លើយបានធ្វើលិខិតធ្វើអំណោយបែងចែកដីផ្តាច់ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ ឲ្យទៅដើមចោទទេ ព្រោះថាដីដែលដើមចោទទាមទារមានទំហំ ៦០ម៉ែត្រ គុណនឹង ១០០ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់នឹងឈ្មោះ [redacted] ម៉ៅ ខាងត្បូងទល់នឹងឈ្មោះ [redacted] ម៉ៅ ខាងកើតទល់នឹងឈ្មោះ [redacted] សារ៉ូ និងខាងលិចទល់នឹងឈ្មោះ [redacted] សំអុល មានទីតាំងស្ថិតនៅភូមិព្រៃគប់ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ គឺយោងតាមពាក្យស្នើសុំបញ្ជាក់ការកាន់កាប់ និងប្រើប្រាស់ដីធ្លីលេខ ១៩១ ពគ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៩ ។ ចំណែកដីដែលចុងចម្លើយប្រគល់ឲ្យទៅដើមចោទមានទំហំ ៨០ម៉ែត្រ គុណនឹង ៦០ម៉ែត្រ តាមលិខិតធ្វើអំណោយបែងចែកដីផ្តាច់ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ ពុំមានបញ្ជាក់ព្រំប្រទល់ទេ ។

## សំអាងហេតុ

**១.ការវិនិច្ឆ័យអំពីចំណុចវិវាទ:**

១.១.តាមការអះអាងរបស់សហដើមចោទបានអះអាងថា ដីទំហំទទឹង៨០ម៉ែត្រ បណ្តោយប្រមាណ ៦០ម៉ែត្រ ស្មើផ្ទៃក្រឡា២៤០០ ម៉ែត្រការ៉េ ស្ថិតនៅភូមិព្រៃគប់ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដែលមាននៅក្នុងចំណុចទី២ នៃលិខិតធ្វើអំណោយបែងចែកដីផ្តាច់លេខ ៣៧៦/១៨ ឃទព ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ បញ្ជាក់ដោយមេឃុំទួលពង្រ ជាដីតែមួយនឹងដីទំហំ ៦០ម៉ែត្រ គុណនឹង ១០០ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់នឹងឈ្មោះ [redacted] ម៉ៅ ខាងត្បូងទល់នឹងឈ្មោះ [redacted] ម៉ៅ ខាងកើតទល់នឹងឈ្មោះ [redacted] សារ៉ូ និងខាងលិចទល់នឹងឈ្មោះ [redacted] សំអុល មានទីតាំងស្ថិតនៅភូមិព្រៃគប់ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដែលមាននៅក្នុងពាក្យស្នើសុំបញ្ជាក់ការកាន់កាប់ និងប្រើប្រាស់ដីធ្លីលេខ ១០៦០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៩ បញ្ជាក់ដោយចៅសង្កាត់ប៉ោយប៉ែត ដែលដីនេះជាទ្រព្យដោយឡែករបស់ឈ្មោះ [redacted] ផល ត្រូវជាឪពុករបស់សហដើមចោទ ។

ទំព័រទី៦

១.២.តាមការអះអាងរបស់សហចុងចម្លើយ បានអះអាងថា ដីទំហំ ៦០ម៉ែត្រ គុណនឹង ១០០ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់នឹងឈ្មោះ [redacted] ម៉ៅ ខាងត្បូងទល់នឹងឈ្មោះ [redacted] ម៉ៅ ខាងកើតទល់នឹងឈ្មោះ [redacted] សារ៉ូ និងខាងលិចទល់នឹងឈ្មោះ [redacted] សំអុល មានទីតាំងស្ថិតនៅភូមិព្រៃគប់ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ជាដីនេះជាទ្រព្យរួមរបស់ចុងចម្លើយ និងឈ្មោះ [redacted] ផល ស្របតាមមាត្រា ៩៧២ និងមាត្រា ៩៧៣ នៃក្រមរដ្ឋប្បវេណី ហើយដីនេះពុំមែនជាដីដែលចុងចម្លើយបានធ្វើលិខិតធ្វើអំណោយបែងចែកដីផ្តាច់ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ ឲ្យទៅដើមចោទទេ ព្រោះថាដីដែលដើមចោទទាមទារមានទំហំ ៦០ម៉ែត្រ គុណនឹង ១០០ម៉ែត្រ ចំណែកដីដែលចុងចម្លើយប្រគល់ឲ្យទៅដើមចោទមានទំហំ ៤០ម៉ែត្រ គុណនឹង ៦០ម៉ែត្រ ។

១.៣.ផ្អែកតាមការអះអាងរបស់គូភាគី ឃើញថា គូភាគីទទួលស្គាល់ពិតជាធ្វើលិខិតធ្វើអំណោយបែងចែកដីផ្តាច់លេខ ៣៧៦/១៨ ឃទព ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ បញ្ជាក់ដោយមេឃុំទួលពង្រ ដោយមានចុងចម្លើយបានប្រគល់ដីពីរកន្លែងឱ្យទៅឈ្មោះ [redacted] សុខឡេង និងឈ្មោះ [redacted] ចក់ ប្រាកដមែន ដោយដីទី១ ក្បាលដីលេខ១១៥ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១០ ទំហំ ២០ម៉ែត្រ បណ្តោយ ២៤០ ម៉ែត្រ ស្មើនឹងផ្ទៃក្រឡា ៤៨០០ ម៉ែត្រការ៉េ មានព្រំប្រទល់ខាងជើងទល់នឹង [redacted] ខេន ខាងត្បូងទល់ផ្លូវ ខាងកើតទល់នឹង [redacted] វ៉ុង ខាងលិចទល់នឹង [redacted] សាលួក ស្ថិតនៅភូមិសន្តិភាព ឃុំទួលពង្រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ និងដីទី២ ទំហំទទឹង ៤០ម៉ែត្រ បណ្តោយប្រមាណ ៦០ម៉ែត្រ ស្មើផ្ទៃក្រឡា២៤០០ ម៉ែត្រការ៉េ ស្ថិតនៅភូមិព្រៃគប់ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ។ ផ្អែកតាមការពិនិត្យភស្តុតាងឃើញថា ឈ្មោះ [redacted] ផល ពុំមានដីផ្សេងដែលស្ថិតនៅភូមិព្រៃគប់ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ក្រៅពីដីទំហំ ៦០ម៉ែត្រ គុណនឹង ១០០ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់នឹងឈ្មោះ [redacted] ម៉ៅ ខាងត្បូងទល់នឹងឈ្មោះ [redacted] ម៉ៅ ខាងកើតទល់នឹងឈ្មោះ [redacted] សារ៉ូ និងខាងលិចទល់នឹងឈ្មោះ [redacted] សំអុល មានទីតាំងស្ថិតនៅភូមិព្រៃគប់ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដែលមានពាក្យស្នើសុំបញ្ជាក់ការកាន់កាប់ និងប្រើប្រាស់ដីធ្លីលេខ ១០៦០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៤ បញ្ជាក់ដោយចៅសង្កាត់ប៉ោយប៉ែតនេះទេ ដែលស៊ីសង្វាក់ទៅនឹងការអះអាងរបស់សហដើមចោទបានអះអាងថា ដីទំហំ ៦០ម៉ែត្រ គុណនឹង ១០០ម៉ែត្រ មានទីតាំងស្ថិតនៅភូមិព្រៃគប់ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ជាដីដែលបានបែងចែកដូចមាននៅក្នុងលិខិតធ្វើអំណោយបែងចែកដីផ្តាច់លេខ ៣៧៦/១៨ ឃទព ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ បញ្ជាក់ដោយមេឃុំទួលពង្រ ចំពោះទំហំដីដែលបានដាក់ក្នុងលិខិតធ្វើអំណោយបែងចែកដីផ្តាច់ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ ដែលបានដាក់ថាដីមានទំហំ ៤០ម៉ែត្រ គុណនឹង ៦០ម៉ែត្រ គឺចេះតែដាក់ស្មានៗតែប៉ុណ្ណោះ ពុំបានវាស់វែងឲ្យ

បានត្រឹមត្រូវទេ និងពុំមានឯកសារយោងច្បាស់លាស់ ក្រោយមកទើបបានឃើញឯកសារជាពាក្យស្នើសុំបញ្ជាក់ការកាន់កាប់ និងប្រើប្រាស់ដីធ្លីលេខ ១០៦០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៤ បង្ហាញថា ដីនេះមានទំហំ ៦០ម៉ែត្រ គុណនឹង ១០០ម៉ែត្រ ។ ចំពោះការអះអាងរបស់ចុងចម្លើយដែលបានអះអាងថា ដីនេះពុំមែនជាដីដែលចុងចម្លើយបានធ្វើលិខិតធ្វើអំណោយបែងចែកដីផ្ដាច់ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ ឲ្យទៅដើមចោទនោះទេ ព្រោះថាដីដែលដើមចោទទាមទារមានទំហំ ៦០ម៉ែត្រ គុណនឹង ១០០ម៉ែត្រ ចំណែកដីដែលចុងចម្លើយប្រគល់ឲ្យទៅដើមចោទមានទំហំ ៤០ម៉ែត្រ គុណនឹង ៦០ម៉ែត្រ ឃើញថា ពុំមានភស្ដុតាងណាមួយដែលបញ្ជាក់ថា ឈ្មោះ [redacted] ផល មានដីផ្សេងដែលស្ថិតនៅភូមិព្រៃគប់ សង្កាត់ផ្សារកណ្ដាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ក្រៅពីដីដែលសហដើមចោទទាមទារនេះទេ ចំពោះការខុសទំហំដីជាការភ័ន្ដច្រឡំដោយពុំបានវាស់វែងឲ្យបានច្បាស់លាស់មុនពេលធ្វើលិខិតធ្វើអំណោយបែងចែកដីផ្ដាច់ និងពុំមានឯកសារដើម្បីធ្វើការផ្ទៀងផ្ទាត់ ដែលគប្បីតុលាការទទួលស្គាល់ការអះអាងរបស់សហដើមចោទ ។

១.៤.ផ្អែកតាមការអះអាងរបស់ដើមចោទ និងការទទួលស្គាល់របស់ចុងចម្លើយ ឃើញថា ចុងចម្លើយ និងឈ្មោះ [redacted] ផល ជាប្ដីប្រពន្ធនឹងគ្នា តែពុំបានទៅចុះសំបុត្រអាពាហ៍ពាហ៍ ដូចនេះ ឃើញថា អាពាហ៍ពិពាហ៍រវាងចុងចម្លើយ និងឈ្មោះ [redacted] ផល ពុំមានអានុភាពតាមផ្លូវច្បាប់នោះទេ ។ តាមពាក្យស្នើសុំបញ្ជាក់ការកាន់កាប់ និងប្រើប្រាស់ដីធ្លីលេខ ១០៦០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៤, លិខិតបញ្ជាក់អំពីសាក្សីព្រំប្រទល់លេខ ១០៦០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៤ បញ្ជាក់ដោយចៅសង្កាត់ប៉ោយប៉ែត, កំណត់ហេតុអង្កេតដីធ្លី ចុះថ្ងៃ១៩ ខែមិថុនា ឆ្នាំ២០០៤ និងពាក្យសុំវាស់វែងដីធ្លី ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៤ ឃើញថា មានតែឈ្មោះ [redacted] ផល តែម្នាក់គត់ដែលជាម្ចាស់ដី ដោយពុំមានឈ្មោះចុងចម្លើយជាម្ចាស់ដីនោះទេ ។ ចំពោះការអះអាងរបស់ចុងចម្លើយថា ដីទំហំ ៦០ម៉ែត្រ គុណនឹង ១០០ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់នឹងឈ្មោះ [redacted] ម៉ៅ ខាងត្បូងទល់នឹងឈ្មោះ [redacted] ម៉ៅ ខាងកើតទល់នឹងឈ្មោះ [redacted] សារ៉ូ និងខាងលិចទល់នឹងឈ្មោះ [redacted] សំអុល មានទីតាំងស្ថិតនៅភូមិព្រៃគប់ សង្កាត់ផ្សារកណ្ដាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ គឺជាដីដែលចុងចម្លើយ និងឈ្មោះ [redacted] ផល ទិញរួមគ្នាពីឈ្មោះ [redacted] រិន នោះ ពុំមានភស្ដុតាងបញ្ជាក់ការអះអាងនោះទេ ។ ដូចនេះ ឃើញថា ដីទំហំ ៦០ម៉ែត្រ គុណនឹង ១០០ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់នឹងឈ្មោះ [redacted] ម៉ៅ ខាងត្បូងទល់នឹងឈ្មោះ [redacted] ម៉ៅ ខាងកើតទល់នឹងឈ្មោះ [redacted] សារ៉ូ និងខាងលិចទល់នឹងឈ្មោះ [redacted] សំអុល មានទីតាំងស្ថិតនៅភូមិព្រៃគប់ សង្កាត់ផ្សារកណ្ដាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ជាទ្រព្យសម្បត្តិដោយឡែករបស់ឈ្មោះ [redacted] ផល ដែលគប្បីតុលាការទទួលស្គាល់ការអះអាងរបស់សហដើមចោទ ។

**២.ការវិនិច្ឆ័យអំពីការទាមទារៈ**

២.១.តាមសំបុត្រមរណភាពលេខ ០២ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៨ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ឃើញថា ឈ្មោះ [redacted]ផល បានទទួលមរណភាពកាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨ ។

២.២.តាមសេចក្តីចម្លងសំបុត្រកំណើតលេខ ៥៧៣/១៨ អ.បបក ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៨, សំបុត្របញ្ជាក់កំណើតលេខ ២១១៨ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៥ , សំបុត្របញ្ជាក់កំណើតលេខ ២១១៩ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៥ និងសំបុត្របញ្ជាក់កំណើតលេខ ១៣៥ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១២ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំអង្គបូរី ស្រុកអង្គបូរី ខេត្តតាកែវ ឃើញថា សហដើមចោទឈ្មោះ [redacted] សុខឡេង, ឈ្មោះ [redacted] ស្រីនី, ឈ្មោះ [redacted] ស្រីណយ និងឈ្មោះ[redacted]ស្រីនិត មានឪពុកឈ្មោះ [redacted] ផល ។

២.៣.តាមពាក្យស្នើសុំបញ្ជាក់ការកាន់កាប់ និងប្រើប្រាស់ដីធ្លីលេខ ១០៦០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៤, លិខិតបញ្ជាក់អំពីសាក្សីព្រំប្រទល់លេខ ១០៦០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៤ បញ្ជាក់ដោយចៅសង្កាត់ប៉ោយប៉ែត, កំណត់ហេតុអង្កេតដីធ្លី ចុះថ្ងៃ១៩ ខែមិថុនា ឆ្នាំ២០០៤ និងពាក្យសុំវាស់វែងដីធ្លី ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៤ ឃើញថា ដីទំហំ ៦០ម៉ែត្រ គុណនឹង ១០០ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់នឹងឈ្មោះ [redacted] ម៉ៅ ខាងត្បូងទល់នឹងឈ្មោះ [redacted] ម៉ៅ ខាងកើតទល់នឹងឈ្មោះ [redacted] សារ៉ូ និងខាងលិចទល់នឹងឈ្មោះ [redacted] សំអុល មានទីតាំងស្ថិតនៅភូមិព្រៃគប់ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ជាដីរបស់ឈ្មោះ [redacted] ផល ។

២.៤.តាមលិខិតធ្វើអំណោយបែងចែកដីផ្តាច់លេខ៣៧៦/១៨ ឃទព ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ បញ្ជាក់ដោយមេឃុំទួលពង្រ ឃើញថា សហចុងចម្លើយបានព្រមព្រៀងប្រគល់ដីទំហំទទឹង ៤០ម៉ែត្រ បណ្តោយប្រមាណ ៦០ម៉ែត្រ ស្មើផ្ទៃក្រឡា២៤០០ ម៉ែត្រការ៉េ ស្ថិតនៅភូមិព្រៃគប់ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ឱ្យទៅឈ្មោះ [redacted] សុខឡេង និងឈ្មោះ [redacted] ចក់ ។

<u>ការសន្និដ្ឋាន:</u> ផ្អែកតាមសំអាងហេតុខាងលើ ឃើញថា ដីទំហំ ៦០ម៉ែត្រ គុណនឹង ១០០ ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់នឹងឈ្មោះ [redacted] ម៉ៅ ខាងត្បូងទល់នឹងឈ្មោះ [redacted] ម៉ៅ ខាងកើតទល់នឹងឈ្មោះ [redacted] សារ៉ូ និងខាងលិចទល់នឹងឈ្មោះ [redacted] សំអុល មានទីតាំងស្ថិតនៅភូមិព្រៃគប់ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ជាដីតែមួយដែលស្ថិតនៅក្នុងចំណុចទី២ នៃលិខិតធ្វើអំណោយបែងចែកដីផ្តាច់លេខ៣៧៦/១៨ ឃទព ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ បញ្ជាក់ដោយមេឃុំទួលពង្រ ដែលចុងចម្លើយបានប្រគល់ឲ្យសហដើមចោទ ។ ផ្អែកតាមពាក្យស្នើសុំបញ្ជាក់ការកាន់កាប់ និងប្រើប្រាស់ដីធ្លីលេខ ១០៦០ ចុះថ្ងៃទី២៨ ខែឧសភា

ឆ្នាំ២០០៤, លិខិតបញ្ជាក់អំពីសាក្សីព្រំប្រទល់លេខ ១០៦០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៤ បញ្ជាក់ដោយចៅសង្កាត់ប៉ោយប៉ែត, កំណត់ហេតុអង្កេតដីធ្លី ចុះថ្ងៃ១៩ ខែមិថុនា ឆ្នាំ២០០៤ និងពាក្យសុំវាស់វែងដីធ្លី ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៤ ឃើញថា ដីទំហំ ៦០ម៉ែត្រ គុណនឹង ១០០ ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់នឹងឈ្មោះ [redacted] ម៉ៅ ខាងត្បូងទល់នឹងឈ្មោះ [redacted] ម៉ៅ ខាងកើតទល់នឹងឈ្មោះ [redacted] សារ៉ូ និងខាងលិចទល់នឹងឈ្មោះ [redacted] សំអុល មានទីតាំងស្ថិតនៅភូមិព្រៃគប់ សង្កាត់ផ្សារកណ្ដាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ជាទ្រព្យសម្បត្តិដោយឡែករបស់ឈ្មោះ [redacted] ផល ។ ឈ្មោះ [redacted] ផល បានទទួលមរណភាព នាំឱ្យកូនៗរបស់ឈ្មោះ [redacted] ផល ដែលសហដើមចោទក្លាយជាសន្តិតិជនដែលមានលំដាប់ទី១ ដែលត្រូវទទួលបន្តនូវមតិកជាដី ទំហំ ៦០ម៉ែត្រ គុណនឹង ១០០ម៉ែត្រ ស្ថិតនៅភូមិព្រៃគប់ សង្កាត់ផ្សារកណ្ដាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដែលបន្សល់ទុកពីមតកជនឈ្មោះ [redacted] ផល ស្របតាមមាត្រា ១១៥៦ នៃក្រមរដ្ឋប្បវេណី ។ ដូចនេះ ការទាមទាររបស់សហដើមចោទ ធ្វើឡើងត្រឹមត្រូវស្របតាមមាត្រា ២៣៦, មាត្រា ២៣៧ នៃក្រមរដ្ឋប្បវេណី គប្បីទទួលស្គាល់ការទាមទាររបស់សហដើមចោទ ។

**៣.អំពីការទាមទារសំណងជម្ងឺចិត្ត ការខាតបង់ពេលវេលា:**

-សហដើមចោទទាមទារឱ្យចុងចុងចម្លើយសងសំណងការខាត ឃើញថា ធ្វើឡើងត្រឹមត្រូវតាមមាត្រា ២៣៩ នៃក្រមរដ្ឋប្បវេណី ដែលគប្បីតុលាការពិចារណាក្នុងកម្រិតមួយសមរម្យ ។ ចំពោះការទាមទារជម្ងឺចិត្តគប្បីច្រានចោល ។

**៤.ស្ដីពីបន្ទុកនៃប្រាក់ប្រដាប់ក្ដី:** គប្បីឲ្យចុងចម្លើយជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្ដី តាមបញ្ញត្តិមាត្រា៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

**សរុបជារួម តុលាការនឹងសម្រេចអំពីរឿងក្ដីស្ដីពីការទាមទារឱ្យទទួលស្គាល់ និងប្រគល់ដី នៃរឿងក្ដីនេះដូចខាងក្រោម:**

## សេចក្ដីសម្រេចបញ្ចប់

១/-ទទួលស្គាល់ដីទំហំ ៦០ម៉ែត្រ គុណនឹង ១០០ ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់នឹងឈ្មោះ [redacted] ម៉ៅ ខាងត្បូងទល់នឹងឈ្មោះ [redacted] ម៉ៅ ខាងកើតទល់នឹងឈ្មោះ [redacted] សារ៉ូ និងខាងលិចទល់នឹងឈ្មោះ [redacted] សំអុល មានទីតាំងស្ថិតនៅភូមិព្រៃគប់ សង្កាត់ផ្សារកណ្ដាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដែលមានពាក្យស្នើសុំបញ្ជាក់ការកាន់កាប់ និងប្រើប្រាស់ដីធ្លី ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៤ ដោយមានការបញ្ជាក់លេខ ១០៦០ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៤ របស់មេឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ជាទ្រព្យដោយឡែករបស់សពឈ្មោះ [redacted] ផល ជាឪពុករបស់សហដើមចោទ ។

២/-បង្គាប់ឲ្យចុងចម្លើយប្រគល់ដីខាងលើនេះមកឲ្យសហដើមចោទ ។



Scanned with CamScanner

៣/-បង្គាប់ឲ្យចុងចម្លើយសងសំណងការខូចខាតជាប្រាក់ចំនួន១០.០០០.០០០ (ដប់លាន) រៀល ទៅឲ្យសហដើមចោទ ។

៤/-ឲ្យចុងចម្លើយទទួលបន្ទុកប្រាក់ប្រដាប់ក្តី ។

សាលក្រមនេះត្រូវបានប្រកាសនៅសវនាការជាសាធារណៈ នៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២០ ។ ករណីដែលប្តឹងឧទ្ធរណ៍ ត្រូវតែធ្វើឡើងនៅក្នុងរយៈ ០១ (មួយ) ខែ គិតចាប់ពីថ្ងៃដែលបានទទួលការបញ្ជូនលិខិតសាលក្រមនេះ ។

**ចៅក្រមជំនុំជម្រះ**

**ហត្ថលេខា និងត្រា [redacted]**

---

*បានចម្លងត្រឹមត្រូវតាមច្បាប់ដើម*

*ថ្ងៃចន្ទ ១៤កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ពស ២៥៦៤*

*បន្ទាយមានជ័យ, ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២០*

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

[redacted]